រដ្ឋសភា
ចូល លេខ ១៧/៦១ ថ្ងៃទី [illegible] ឆ្នាំ២០១៣ ម៉ោង [illegible] បញ្ជូនទៅ [illegible]

# ព្រះរាជក្រម

នស/រកម/០៦១៣/០០៦

យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សម្ពហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ ព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ ព្រះរាជក្រមលេខ នស/រកម/០១៩៦/២៧ ចុះថ្ងៃទី២៦ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃធនាគារជាតិនៃកម្ពុជា
- បានទ្រង់យល់ សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា និងអគ្គទេសាភិបាលធនាគារជាតិនៃកម្ពុជា

## ប្រកាសឱ្យប្រើ

ច្បាប់ ស្តីពីវិសោធនកម្មមាត្រា៣ មាត្រា២៩ និងមាត្រា៣០ នៃច្បាប់ស្តីពីការប្រឆាំងការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម ដែលរដ្ឋសភាបានអនុម័ត កាលពីថ្ងៃទី៨ ខែឧសភា ឆ្នាំ២០១៣ នាសម័យប្រជុំរដ្ឋសភាលើកទី៩ នីតិកាលទី៤ និងដែលព្រឹទ្ធសភាបានយល់ស្របតាមទម្រង់ និងគតិនៃច្បាប់នេះទាំងស្រុង ដោយគ្មានការកែប្រែអ្វីឡើយ កាលពីថ្ងៃទី១៧ ខែឧសភា ឆ្នាំ២០១៣ នាសម័យប្រជុំវិសាមញ្ញ នីតិកាលទី៣ ហើយដែលមានសេចក្តីទាំងស្រុងដូចតទៅនេះ ៖

ROYAUME DU CAMBODGE • LE MINISTRE DU PALAIS ROYAL •
ព្រះបរមរាជវាំង

# ច្បាប់

## ស្តីពី

## វិសោធនកម្មមាត្រា៣ មាត្រា២៩ និងមាត្រា៣០ នៃច្បាប់ស្តីពីការប្រឆាំងការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

**មាត្រាមួយ.-**

មាត្រា៣ មាត្រា២៩ និងមាត្រា៣០ នៃច្បាប់ស្តីពីការប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម ដែលប្រកាសឲ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០៦០៧/០១៤ ចុះថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០០៧ ត្រូវបានធ្វើវិសោធនកម្មដូចតទៅ ៖

**មាត្រា ៣ថ្មី.- និយមន័យនៃពាក្យបច្ចេកទេស**

ទោះបីមានបទប្បញ្ញត្តិច្បាប់ផ្សេងទៀតក៏ដោយពាក្យថា ៖

ក- ការសម្អាតប្រាក់ គឺជា ៖

១- ការបំប្លែងឬការផ្ទេរទ្រព្យសម្បត្តិ ដោយដឹងថាទ្រព្យសម្បត្តិនេះជាផលនៃបទល្មើសក្នុងគោលបំណងបិទបាំងឬក្លែងប្រភពដើម មិនស្របច្បាប់នៃទ្រព្យសម្បត្តិទាំងនេះ ឬជួយបុគ្គលណាដែលបានពាក់ព័ន្ធក្នុងបទល្មើស ដើម្បីឲ្យបុគ្គលនោះគេចផុតពីផលវិបាកតាមផ្លូវច្បាប់នូវសកម្មភាពរបស់ខ្លួន ។

២- ការបិទបាំងឬការក្លែងសភាវៈពិត ប្រភព ទីតាំង សិទ្ធិចាត់ចែង ចលនា ឬកម្មសិទ្ធិឬសិទ្ធិលើទ្រព្យសម្បត្តិ ដោយដឹងថាទ្រព្យសម្បត្តិទាំងនេះបានមកពីបទល្មើស ។

៣- ការធ្វើលទ្ធកម្ម ការកាន់កាប់ ឬការប្រើប្រាស់ទ្រព្យសម្បត្តិ ដោយដឹងថាទ្រព្យសម្បត្តិទាំងនេះបានមកពីបទល្មើស ។

៤- ការចូលរួម ការប៉ុនប៉ងប្រព្រឹត្ត ដោយជួយនិងជំរុញឲ្យប្រព្រឹត្តសកម្មភាពណាមួយដែលបានកំណត់ស្របតាមមាត្រា៣ នៃច្បាប់នេះ ។

ខ- ផលនៃបទល្មើស គឺជាទ្រព្យសម្បត្តិណាដែលបានឬទទួលដោយផ្ទាល់ឬដោយប្រយោលតាមរយៈការប្រព្រឹត្តបទល្មើសឧក្រិដ្ឋឬបទល្មើសមជ្ឈិម ។

គ- ទ្រព្យសម្បត្តិ គឺជាទ្រព្យគ្រប់ប្រភេទ ចលនទ្រព្យឬអចលនទ្រព្យរូបិយឬអរូបិយ និងឯកសារឬឧបករណ៍គតិយុត្តិ ដែលជាភស្តុតាងនៃកម្មសិទ្ធិឬអត្ថប្រយោជន៍លើទ្រព្យទាំងនេះ ។

ទ្រព្យសម្បត្តិរួមបញ្ចូលឧបករណ៍និងផលបានមកពីការសម្អាតប្រាក់ ហិរញ្ញប្បទានភេរវកម្ម និងបទល្មើសធ្ងន់ធ្ងរផ្សេងៗ ។ ទ្រព្យសម្បត្តិរួមបញ្ចូលទ្រព្យសម្បត្តិជំនួសរបស់រូបវន្តបុគ្គលឬនីតិបុគ្គលដែលមានតម្លៃស្មើនឹងទ្រព្យសម្បត្តិដែលជាកម្មវត្ថុនៃការបង្កក ការឃាត់ទុក និងការរឹបអូស ។

ROYAUME DU CAMBODGE • LE MINISTRE DU PALAIS ROYAL

ឃ- **ស្ថាប័នត្រួតពិនិត្យ** គឺជាធនាគារជាតិនៃកម្ពុជា គណៈកម្មការមូលបត្រនិងស្ថាប័នផ្សេងទៀត ដែលត្រួតពិនិត្យលើបុគ្គលរាយការណ៍ ។

ង- **សំអាងនៃបទល្មើស** គឺជាបទល្មើសឧក្រិដ្ឋឬបទល្មើសមជ្ឈិម ទោះជាបានប្រព្រឹត្តនៅក្រៅប្រទេស ដែលផលទទួលបានពីបទល្មើសទាំងនេះអាចក្លាយជាកម្មវត្ថុនៃការសម្អាតប្រាក់ ដូចបានកំណត់នៅក្នុងកថាខណ្ឌ (ក) នៃមាត្រា៣ នៃច្បាប់នេះ ។

ដើម្បីអាចយកមកប្រើប្រាស់ជាមូលដ្ឋាន សម្រាប់ប្តឹងអំពីការសម្អាតប្រាក់ សំអាងនៃបទល្មើស ដែលត្រូវបានប្រព្រឹត្តនៅក្រៅប្រទេស ត្រូវមានចរិតជាបទល្មើសនៅក្នុងប្រទេស ដែលបទល្មើស នេះត្រូវបានប្រព្រឹត្តនិងស្ថិតនៅក្រោមច្បាប់នៃព្រះរាជាណាចក្រកម្ពុជា លើកលែងតែមានកិច្ចព្រមព្រៀងពិសេសផ្សេងពីនេះ ។

សំអាងនៃបទល្មើស មានដូចខាងក្រោម ៖

- ការចូលរួមក្នុងក្រុមឧក្រិដ្ឋជន ដែលមានការចាត់តាំង និងការប្រកបរបរអាជីវកម្មទុច្ចរិត
- ភេរវកម្ម រួមទាំងហិរញ្ញប្បទានភេរវកម្ម
- ការជួញដូរមនុស្សនិងទេសន្តរប្រវេសន៍
- ការជួញដូរផ្លូវភេទ រួមទាំងការជួញដូរផ្លូវភេទលើកុមារ
- ការជួញដូរខុសច្បាប់នូវគ្រឿងញៀនណាកូទិក និងសារធាតុញៀន
- ការជួញដូរអាវុធខុសច្បាប់
- ការជួញដូរខុសច្បាប់នូវទំនិញដែលបានលួច និងទំនិញផ្សេងទៀត
- អំពើពុករលួយនិងសំណូក
- ការបន្លំលួច
- ការក្លែងរូបិយប័ណ្ណ
- ការក្លែងនិងការលួចចម្លងផលិតផល
- បទល្មើសបរិស្ថានឬការកាប់ឈើខុសច្បាប់
- ការធ្វើឃាត ការបង្ករបួសដល់រាងកាយធ្ងន់ធ្ងរ
- ការចាប់ជំរិត ការឃុំខ្លួនខុសច្បាប់ និងចំណាប់ខ្មាំង
- ការប្លន់ឬការលួច
- ការគេចពន្ធ
- ការគំរាមកំហែង

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL



Ksl

- ការក្លែងបន្លំឯកសារ
- អំពើប្លន់តាមសមុទ្រ
- ការគេចពន្ធ និង
- ការធ្វើជំនួញជាអ្នកក្នុងនិងការបោកបញ្ឆោតទីផ្សារ ។

ច- **ហិរញ្ញប្បទានភេរវកម្ម** គឺជាការផ្តល់ឬការប្រមូលដោយចេតនានូវសេវាហិរញ្ញវត្ថុឬសេវាផ្សេងទៀត ក្នុងបំណងប្រើប្រាស់សេវានេះឬដោយដឹងថាមូលនិធិនេះនឹងត្រូវបានឬអាចប្រើទាំងមូលឬមួយផ្នែកសម្រាប់គាំទ្រភេរវកម្ម សកម្មភាពរបស់ភេរវករឬអង្គការចាត់តាំងរបស់ភេរវកម្ម ។

ឆ- **ប្រតិបត្តិការសង្ស័យ** គឺជាប្រតិបត្តិការទាក់ទងទៅនឹងមូលនិធិ ដែលត្រូវបានសង្ស័យថាបានមកពីការប្រព្រឹត្តបទល្មើសឬជាមូលនិធិទាក់ទងនឹងហិរញ្ញប្បទានភេរវកម្ម ។

ជ- **អង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុ** គឺជាអង្គការកណ្តាលដែលទទួលខុសត្រូវក្នុងការទទួលវិភាគនិងផ្សព្វផ្សាយរបាយការណ៍ស្តីពីប្រតិបត្តិការសង្ស័យ ដូចបានកំណត់នៅក្នុងកថាខណ្ឌ (ឆ) នៃមាត្រា៣ នៃច្បាប់នេះ ប្រតិបត្តិការសាច់ប្រាក់ដូចបានកំណត់នៅក្នុងកថាខណ្ឌ ១ នៃមាត្រា១២ នៃច្បាប់នេះ និងព័ត៌មានផ្សេងទៀតពាក់ព័ន្ធនឹងការសម្អាតប្រាក់ឬហិរញ្ញប្បទានភេរវកម្ម ។

ឈ-**អត្ថគាហកចុងក្រោយ** គឺជាបុគ្គលដែលកាន់កាប់ឬត្រួតត្រាចុងក្រោយបង្អស់លើអតិថិជននិង/ឬបុគ្គលដែលធ្វើប្រតិបត្តិការជំនួស រាប់បញ្ចូលទាំងបុគ្គលទាំងឡាយដែលកំពុងធ្វើប្រតិបត្តិការ ជាចុងក្រោយលើនីតិបុគ្គលឬកិច្ចសម្របសម្រួលណាមួយ ។

ញ- **បុគ្គលពាក់ព័ន្ធនយោបាយ** គឺជាឯកត្តជនដែលជាឬដែលត្រូវបានប្រគល់មុខងារសាធារណៈខ្ពង់ខ្ពស់នៅក្រៅប្រទេស ដូចជាប្រមុខរដ្ឋឬប្រមុខរដ្ឋាភិបាល អ្នកនយោបាយជាន់ខ្ពស់ មន្ត្រីរដ្ឋាភិបាលជាន់ខ្ពស់ មន្ត្រីយោធាឬមន្ត្រីយុត្តិធម៌ នាយកប្រតិបត្តិជាន់ខ្ពស់នៃសាជីវកម្មរដ្ឋឬមន្ត្រីគណបក្សសំខាន់ៗ ។

ដ- **ក្រុមហ៊ុនអាណត្តិព្យាបាល** គឺជានីតិបុគ្គលដែលត្រូវបានបង្កើតឡើងដោយបុគ្គលម្នាក់ដែលជាអ្នកប្រគល់អាណត្តិព្យាបាល ។ អ្នកប្រគល់អាណត្តិព្យាបាលផ្ទេរកម្មសិទ្ធិស្របច្បាប់នៃទ្រព្យសម្បត្តិទៅឲ្យអ្នកទទួលអាណត្តិព្យាបាលដែលធ្វើការគ្រប់គ្រងទ្រព្យសម្បត្តិនោះសម្រាប់ជាផលប្រយោជន៍ដល់អត្ថគាហកណាម្នាក់ច្បាស់លាស់ ។

ឋ- **ទុច្ចរិតកម្ម** គឺការធ្វើឲ្យទៅជាមោឃៈ ។

## មាត្រា ២៩ថ្មី១.- បទសម្អាតប្រាក់

ការសម្អាតប្រាក់ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ២ (ពីរ) ឆ្នាំទៅ ៥ (ប្រាំ) ឆ្នាំ និង ពិន័យជាប្រាក់ពី ៤០ ០០០ ០០០ (សែសិបលាន) រៀល រហូតដល់ស្មើ ១០០ ០០០ ០០០ (មួយរយលាន) រៀល ឬរហូតដល់ស្មើនឹងតម្លៃមូលនិធិឬទ្រព្យសម្បត្តិដែលជាកម្មវត្ថុនៃការសម្អាតប្រាក់ ។

បទប្បញ្ញត្តិពីមាត្រា៤០៦ (ស្ថានទម្ងន់ទោស) ដល់មាត្រា៤០៨ (ទោសបន្ថែម ៖ ប្រភេទនិងរយៈពេល) នៃក្រមព្រហ្មទណ្ឌ ត្រូវយកមកអនុវត្ត ។

នីតិបុគ្គលអាចត្រូវប្រកាសថា ត្រូវទទួលខុសត្រូវព្រហ្មទណ្ឌតាមលក្ខខណ្ឌដែលមានចែងក្នុងមាត្រា៤២ (ការទទួលខុសត្រូវព្រហ្មទណ្ឌរបស់នីតិបុគ្គល) នៃក្រមព្រហ្មទណ្ឌសម្រាប់បទល្មើសសម្អាតប្រាក់ ។

នីតិបុគ្គលត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពី ១០០ ០០០ ០០០ (មួយរយលាន) រៀល ទៅ ៥០០ ០០០ ០០០ (ប្រាំរយលាន) រៀល ព្រមទាំងទោសបន្ថែមណាមួយឬច្រើន ដូចមានចែងនៅក្នុងមាត្រា២៩ ថ្មី៦ (ទោសបន្ថែមអនុវត្តចំពោះនីតិបុគ្គល) នៃច្បាប់នេះ ។

## មាត្រា ២៩ថ្មី២.- ការបដិសេធផ្តល់ព័ត៌មាន

បុគ្គលណាដែលមានចេតនាមិនផ្តល់ព័ត៌មានដល់អង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជា និងស្ថាប័នត្រួតពិនិត្យដូចមានចែងក្នុងមាត្រា៦ នៃច្បាប់ស្តីពីការប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី៦ (ប្រាំមួយ) ថ្ងៃ ដល់១ (មួយ) ខែ និងផ្តន្ទាទោសពិន័យជាប្រាក់ពី ១០០ ០០០ (មួយសែន) រៀល ដល់១ ០០០ ០០០ (មួយលាន) រៀល ឬ ទោសណាមួយនៃទោសទាំងពីរ ។

នីតិបុគ្គលអាចត្រូវប្រកាសថា ត្រូវទទួលខុសត្រូវព្រហ្មទណ្ឌតាមលក្ខខណ្ឌដែលមានចែងក្នុងមាត្រា៤២ (ការទទួលខុសត្រូវព្រហ្មទណ្ឌរបស់នីតិបុគ្គល) នៃក្រមព្រហ្មទណ្ឌចំពោះបទល្មើសដែលបានប្រព្រឹត្តនៅក្នុងកថាខណ្ឌ១ នៃមាត្រានេះ ។

នីតិបុគ្គលត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពី ១ ០០០ ០០០ (មួយលាន) រៀលទៅ ២ ០០០ ០០០ (ពីរលាន) រៀល ព្រមទាំងទោសបន្ថែមណាមួយឬច្រើន ដូចមានចែងនៅក្នុងមាត្រា២៩ថ្មី៦ (ទោសបន្ថែម អនុវត្តចំពោះនីតិបុគ្គល) នៃច្បាប់នេះ ។

## មាត្រា ២៩ថ្មី៣.- ការខកខានមិនបានធ្វើរបាយការណ៍ប្រតិបត្តិការ

បុគ្គលណាដែលមានចេតនាមិនបានរាយការណ៍អំពីប្រតិបត្តិការសាច់ប្រាក់ឬប្រតិបត្តិការសង្ស័យទៅអង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជា ដូចមានចែងក្នុងមាត្រា១២ នៃច្បាប់ស្តីពីការប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី១ (មួយ) ខែ ដល់ ១ (មួយ) ឆ្នាំ និងផ្តន្ទាទោសពិន័យជាប្រាក់ពី ១ ០០០ ០០០ (មួយលាន) រៀល ដល់ ៥ ០០០ ០០០ (ប្រាំលាន) រៀល ឬទោសណាមួយនៃទោសទាំងពីរ ។

នីតិបុគ្គលអាចត្រូវប្រកាសថា ត្រូវទទួលខុសត្រូវព្រហ្មទណ្ឌតាមលក្ខខណ្ឌដែលមានចែងក្នុងមាត្រា៤២ (ការទទួលខុសត្រូវព្រហ្មទណ្ឌរបស់នីតិបុគ្គល) នៃក្រមព្រហ្មទណ្ឌចំពោះបទល្មើស ដែលបានប្រព្រឹត្តនៅក្នុងកថាខណ្ឌ១ នៃមាត្រានេះ ។

នីតិបុគ្គលត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពី ២ ០០០ ០០០ (ពីរលាន) រៀលទៅ ៥ ០០០ ០០០ (ប្រាំលាន) រៀល ព្រមទាំងទោសបន្ថែមណាមួយឬច្រើន ដូចមានចែងនៅក្នុងមាត្រា២៩ថ្មី៦ (ទោសបន្ថែមអនុវត្តចំពោះនីតិបុគ្គល) នៃច្បាប់នេះ ។

## មាត្រា ២៩ថ្មី៤.- ការរំលោភកាតព្វកិច្ចផ្តល់ព័ត៌មាននិងការហាមឃាត់ការផ្តល់ព័ត៌មាន

បុគ្គលណាដែលមានកាតព្វកិច្ចផ្តល់ព័ត៌មានឬបញ្ជូនរបាយការណ៍ ដូចមានចែងនៅក្នុងមាត្រា១៣ នៃច្បាប់ស្តីពីការប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្មឬបុគ្គលណាដែលបានដឹងរឿងហើយមានចេតនាផ្តល់ព័ត៌មានឬរាយការណ៍ល្មើសនឹងបទប្បញ្ញត្តិនៃការហាមឃាត់ការផ្តល់ព័ត៌មាន ដូចមានចែងក្នុងមាត្រា១៥ នៃច្បាប់ស្តីពីការប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១ (មួយ) ខែ ដល់ ១ (មួយ) ឆ្នាំ និងផ្តន្ទាទោសពិន័យជាប្រាក់ពី ១ ០០០ ០០០ (មួយលាន) រៀល ដល់៥ ០០០ ០០០ (ប្រាំលាន) រៀល ឬទោសណាមួយ នៃទោសទាំងពីរ ។

នីតិបុគ្គលអាចត្រូវបានប្រកាសថា ត្រូវទទួលខុសត្រូវព្រហ្មទណ្ឌតាមលក្ខខណ្ឌ ដែលមានចែងក្នុងមាត្រា៤២ (ការទទួលខុសត្រូវព្រហ្មទណ្ឌរបស់នីតិបុគ្គល) នៃក្រមព្រហ្មទណ្ឌចំពោះបទល្មើសដែលបានប្រព្រឹត្តនៅក្នុងកថាខណ្ឌ ១ នៃមាត្រានេះ ។

នីតិបុគ្គលត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពី ២ ០០០ ០០០ (ពីរលាន) រៀលទៅ ៥ ០០០ ០០០ (ប្រាំលាន) រៀល ព្រមទាំងទោសបន្ថែមណាមួយឬច្រើន ដូចមានចែងនៅក្នុងមាត្រា២៩ថ្មី៦ (ទោសបន្ថែមអនុវត្តចំពោះនីតិបុគ្គល) នៃច្បាប់នេះ ។

## មាត្រា ២៩ថ្មី៥.- ការរំលោភកាតព្វកិច្ចរក្សាការសម្ងាត់វិជ្ជាជីវៈ

បុគ្គលណាដែលមានចេតនារំលោភកាតព្វកិច្ចរក្សាការសម្ងាត់វិជ្ជាជីវៈ ដូចមានចែងក្នុងមាត្រា២៣ នៃច្បាប់ស្តីពីការប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១ (មួយ) ខែ ដល់ ១ (មួយ) ឆ្នាំ និងផ្តន្ទាទោសពិន័យជាប្រាក់ពី ១ ០០០ ០០០ (មួយលាន) រៀល ដល់ ៥ ០០០ ០០០ (ប្រាំលាន) រៀល ឬទោសណាមួយនៃទោសទាំងពីរ ។

នីតិបុគ្គលអាចត្រូវប្រកាសថា ត្រូវទទួលខុសត្រូវព្រហ្មទណ្ឌតាមលក្ខខណ្ឌដែលមានចែងក្នុងមាត្រា៤២ (ការទទួលខុសត្រូវព្រហ្មទណ្ឌរបស់នីតិបុគ្គល) នៃក្រមព្រហ្មទណ្ឌចំពោះបទល្មើសដែលបានប្រព្រឹត្តនៅក្នុងកថាខណ្ឌ ១ នៃមាត្រានេះ ។

នីតិបុគ្គលត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពី ២ ០០០ ០០០ (ពីរលាន) រៀលទៅ ៥ ០០០ ០០០ (ប្រាំលាន) រៀល ព្រមទាំងទោសបន្ថែមណាមួយឬច្រើន ដូចមានចែងនៅក្នុងមាត្រា២៩ថ្មី៦ (ទោសបន្ថែមអនុវត្តចំពោះនីតិបុគ្គល) នៃច្បាប់នេះ ។

## មាត្រា ២៩ថ្មី៦.- ទោសបន្ថែមអនុវត្តចំពោះនីតិបុគ្គល

នីតិបុគ្គលត្រូវផ្តន្ទាទោសបន្ថែមណាមួយឬច្រើន ដូចតទៅនេះ ៖

១-ការរំលាយតាមបែបបទកំណត់ដោយមាត្រា១៧០ (ការរំលាយនីតិបុគ្គលនិងការជម្រះបញ្ជីនៃនីតិបុគ្គល) នៃក្រមព្រហ្មទណ្ឌ ។

២-ការដាក់ឲ្យស្ថិតក្រោមការតាមដានត្រួតពិនិត្យរបស់តុលាការតាមបែបបទកំណត់ដោយមាត្រា១៧១ (ការដាក់ឲ្យស្ថិតនៅក្រោមការត្រួតពិនិត្យតាមដានរបស់តុលាការ) នៃក្រមព្រហ្មទណ្ឌ ។

៣-ការហាមឃាត់ចំពោះការធ្វើសកម្មភាពមួយឬច្រើនតាមបែបបទកំណត់ដោយមាត្រា១៧២ (ការហាមឃាត់ចំពោះការធ្វើសកម្មភាព)នៃក្រមព្រហ្មទណ្ឌ។

៤-ការបណ្តេញចេញពីលទ្ធកម្មសាធារណៈតាមបែបបទកំណត់ដោយមាត្រា១៧៣ (ការបណ្តេញចេញពីលទ្ធកម្មសាធារណៈ) នៃក្រមព្រហ្មទណ្ឌ ។

៥-ការហាមឃាត់ចំពោះការអំពាវនាវជាសាធារណៈដល់ការសន្សំសំចៃតាមបែបបទកំណត់ដោយមាត្រា១៧៤ (ការហាមឃាត់ចំពោះការធ្វើការអំពាវនាវជាសាធារណៈឲ្យធ្វើការសន្សំសំចៃ) នៃក្រមព្រហ្មទណ្ឌ ។

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

Kol

៦- ការរឹបអូសវត្ថុឬមូលនិធិដែលជាកម្មវត្ថុនៃបទល្មើសតាមបែបបទដែលកំណត់ដោយមាត្រា១៧៨ (ការរឹបអូសកម្មសិទ្ធិ ការលក់ ការបំផ្លាញចោលវត្ថុរឹបអូស) និងមាត្រា១៧៩ (ការរឹបអូស និងសិទ្ធិតតិយជន) នៃក្រមព្រហ្មទណ្ឌ ។

៧- ការរឹបអូសផលទុននិងទ្រព្យសម្បត្តិដែលជាផលកើតចេញពីបទល្មើសតាមបែបបទ ដែលកំណត់ដោយមាត្រា១៧៨ (ការរឹបអូសកម្មសិទ្ធិ ការលក់ ការបំផ្លាញចោលវត្ថុរឹបអូស) និងមាត្រា១៧៩(ការរឹបអូស និងសិទ្ធិតតិយជន) នៃក្រមព្រហ្មទណ្ឌ ។

៨- ការបិទផ្សាយសេចក្ដីសម្រេចផ្ដន្ទាទោសតាមបែបបទកំណត់ដោយមាត្រា១៨០ (ការបិទផ្សាយសេចក្ដីសម្រេច) នៃក្រមព្រហ្មទណ្ឌ ។

៩- ការផ្សាយសេចក្ដីសម្រេចផ្ដន្ទាទោស នៅក្នុងសារព័ត៌មានសរសេរឬការផ្សាយតាមគ្រប់មធ្យោបាយតាមបែបបទកំណត់ដោយមាត្រា១៨១ (ការផ្សាយសេចក្ដីសម្រេចតាមមធ្យោបាយទូរគមនាគមន៍សោតទស្សន៍ជាអាទិ៍) នៃក្រមព្រហ្មទណ្ឌ ។

**មាត្រា ២៩ថ្មី៧.- បទហិរញ្ញប្បទានភេរវកម្ម**

ត្រូវផ្ដន្ទាទោសដាក់ពន្ធនាគារពី ១០ (ដប់) ឆ្នាំ ដល់ ២០ (ម្ភៃ) ឆ្នាំ ចំពោះបុគ្គលណាដែលមានចេតនាផ្ដល់ឬប្រមូលមូលនិធិឬផ្ដល់លទ្ធភាពប្រើប្រាស់ទ្រព្យសម្បត្តិ ធនធាន ឬសេវាកម្ម ដោយផ្ទាល់ឬដោយប្រយោលសម្រាប់អត្ថប្រយោជន៍របស់ ៖

ក. បុគ្គលណាមួយដែលបានប្រព្រឹត្តបទល្មើសដូចមានបញ្ញត្តនៅក្នុងច្បាប់ស្ដីពីការប្រឆាំង នឹងភេរវកម្មឬបទល្មើសស្របគ្នា ក្រោមច្បាប់របស់រដ្ឋបរទេស ឬ

ខ. អង្គភាពដែលជាកម្មសិទ្ធិរបស់ឬដែលត្រូវបានគ្រប់គ្រងដោយផ្ទាល់ឬដោយប្រយោល ដោយបុគ្គលដែលបានបញ្ញត្តនៅក្នុងចំណុច"ក"ខាងលើនេះ ឬ

គ. បុគ្គលឬអង្គភាពដែលធ្វើសកម្មភាពក្នុងនាមឬតាមការបញ្ជារបស់បុគ្គលដែលបានបញ្ញត្តក្នុងចំណុច "ក" ខាងលើនេះ ។

អំពើដែលបានបញ្ញត្តនៅក្នុងកថាខណ្ឌ១ ខាងលើនេះ គឺជាបទល្មើសទោះបីជាទ្រព្យសម្បត្តិឬធនធានឬសេវាកម្មមិនត្រូវបានយកទៅប្រើប្រាស់ដើម្បីប្រព្រឹត្តបទល្មើសដែលមានបញ្ញត្តក្នុងច្បាប់ប្រឆាំងនឹងភេរវកម្មឬបទល្មើសស្របគ្នាក្រោមច្បាប់របស់រដ្ឋបរទេសក៏ដោយ ។

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

នីតិបុគ្គលអាចត្រូវប្រកាសថា ត្រូវទទួលខុសត្រូវព្រហ្មទណ្ឌតាមលក្ខខណ្ឌដែលមានចែងក្នុងមាត្រា៤២ (ការទទួលខុសត្រូវព្រហ្មទណ្ឌរបស់នីតិបុគ្គល) នៃក្រមព្រហ្មទណ្ឌចំពោះបទល្មើស ដែលបានប្រព្រឹត្តនៅក្នុងកថាខណ្ឌ១ នៃមាត្រានេះ ។

នីតិបុគ្គលត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពី ២០ ០០០ ០០០ (ម្ភៃលាន) រៀលទៅ ៤០ ០០០ ០០០ (សែសិបលាន) រៀល ព្រមទាំងទោសបន្ថែមណាមួយឬច្រើន ដូចមានចែងនៅក្នុងមាត្រា២៩ថ្មី៦ (ទោសបន្ថែមអនុវត្តចំពោះនីតិបុគ្គល) នៃច្បាប់នេះ ។

## មាត្រា ៣០ថ្មី១.- ការបង្កកនិងការឃាត់ទុកទ្រព្យសម្បត្តិរបស់បុគ្គល

សមាជិកដែលត្រូវបានចាត់តាំងនៃគណៈកម្មាធិការសម្របសម្រួលថ្នាក់ជាតិប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្មអាចបង្កកទ្រព្យសម្បត្តិនិងចាត់វិធានការបណ្ដោះអាសន្ន សមស្របផ្សេងទៀត កាន់តែឆាប់ដែលអាចធ្វើទៅបាន នៅពេលមានការសង្ស័យឬមានមូលដ្ឋានសមស្របសង្ស័យថាទ្រព្យសម្បត្តិនោះពាក់ព័ន្ធនឹងបទល្មើសឬផលនៃបទល្មើសមុននឹងស្នើសុំសេចក្ដីសម្រេចពីតុលាការក្នុងគោលបំណងរក្សាទុកទ្រព្យសម្បត្តិ ដែលជាកម្មវត្ថុនៃការរឹបអូសដូចមានចែងនៅក្នុងមាត្រា៣០ថ្មី២ (ការរឹបអូសទ្រព្យសម្បត្តិ) នៃច្បាប់នេះ ។

អាជ្ញាធរអនុវត្តច្បាប់ ក្រោយពេលដឹងថា មានវត្តមាននៃទ្រព្យសម្បត្តិដែលពាក់ព័ន្ធឬសង្ស័យ ថាពាក់ព័ន្ធនឹងបទល្មើសឬផលនៃបទល្មើស ត្រូវតែឃាត់ទុកទ្រព្យសម្បត្តិនោះដោយគ្មានបង្អង់ និងយ៉ាងឆាប់តាមដែលអាចធ្វើទៅបាន ហើយប្តឹងសុំទៅតុលាការដើម្បីបង្កកទ្រព្យសម្បត្តិនោះ ។

## មាត្រា ៣០ថ្មី២.- ការរឹបអូសទ្រព្យសម្បត្តិ

ក្នុងស្ថានភាពមានទោសសម្អាតប្រាក់ឬសំអាងនៃបទល្មើសឬហិរញ្ញប្បទានភេរវកម្ម តុលាការអាចចេញបទបញ្ជាឲ្យរឹបអូស ៖

ក- ទ្រព្យសម្បត្តិដែលជាផលបទល្មើស រួមទាំងទ្រព្យសម្បត្តិរួមបញ្ចូលគ្នាឬត្រូវបានផ្លាស់ប្តូរ ជាមួយផលទាំងនោះ

ខ- ទ្រព្យសម្បត្តិដែលជាចំណូលឬអត្ថប្រយោជន៍ផ្សេងទៀតដែលទទួលបានពីផលនៃបទល្មើស

គ- ឧបករណ៍ សម្ភារៈ ឬវត្ថុណាមួយដែលបានប្រើប្រាស់ក្នុងការប្រព្រឹត្តបទល្មើសឧក្រិដ្ឋ

ឃ- ទ្រព្យសម្បត្តិដែលមានចែងនៅចំណុច (ក) (ខ) និង (គ) នៃមាត្រានេះដែលត្រូវបាន ផ្ទេរទៅភាគីណាមួយ លើកលែងតែមានភស្តុតាងបញ្ជាក់ថាម្ចាស់កម្មសិទ្ធិនៃទ្រព្យសម្បត្តិនោះទទួលបានដោយបានបង់ថ្លៃត្រឹមត្រូវឬសម្រាប់ការផ្តល់សេវាត្រឡប់វិញស្របតាមតម្លៃនៃទ្រព្យសម្បត្តិឬលើមូលដ្ឋានស្របច្បាប់ណាមួយផ្សេងទៀត និងថាបុគ្គលនោះ មិនបានដឹងពីប្រភពមិនស្របច្បាប់នៃទ្រព្យសម្បត្តិនោះឬ

ង- ទ្រព្យសម្បត្តិរបស់ចារីដែលពាក់ព័ន្ធបទល្មើសដែលមានតម្លៃស្មើនឹងតម្លៃនៃផលនៃបទល្មើស ។

ក្នុងករណីតុលាការរកឃើញបទល្មើសមានពាក់ព័ន្ធនឹងការសម្អាតប្រាក់ឬសំអាងនៃបទល្មើស ឬហិរញ្ញប្បទានភេរវកម្ម ទោះបីជាចារីមិនទាន់ត្រូវបានផ្តន្ទាទោសដោយសារមិនស្គាល់អត្តសញ្ញាណ ឬស្លាប់ តុលាការនៅតែអាចចេញបញ្ជារឹបអូសទ្រព្យសម្បត្តិដែលត្រូវបានឃាត់ទុក ប្រសិនបើមាន ភស្តុតាងគ្រប់គ្រាន់បញ្ជាក់ថា ទ្រព្យសម្បត្តិនោះជាផលនៃបទល្មើស ។

បន្ថែមពីការរឹបអូសទ្រព្យសម្បត្តិដែលមានចែងក្នុងចំណុច (ក) (ខ) (គ) (ឃ) និង (ង) នៃមាត្រានេះ ការរឹបអូសទ្រព្យសម្បត្តិដែលមានចែងនៅក្នុងក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ក៏ត្រូវបានអនុវត្តផងដែរ ។

**មាត្រា ៣០ថ្មី៣.- ទ្រព្យសម្បត្តិបញ្ចូលគ្នា**

នៅពេលណាដែលទ្រព្យសម្បត្តិដែលជាឬត្រូវបានសង្ស័យដោយសមហេតុផលថាជាទ្រព្យសម្បត្តិដែលទាក់ទងនឹងបទល្មើសឬជាផលនៃបទល្មើស ត្រូវបានដាក់បញ្ចូលជាមួយទ្រព្យសម្បត្តិដទៃទៀតដែលមិនទាក់ទងនឹងបទល្មើសឬផលនៃបទល្មើស ត្រូវបានរឹបអូសតាមបញ្ញត្តិ មាត្រា៣០ថ្មី១ (ការបង្កកនិងការឃាត់ទុកទ្រព្យសម្បត្តិរបស់បុគ្គល) ឬមាត្រា៣០ថ្មី២ (ការរឹបអូសទ្រព្យសម្បត្តិ) នៃច្បាប់នេះ ត្រូវតែមិនលើសតម្លៃនៃទ្រព្យសម្បត្តិដែលជាឬត្រូវបានសង្ស័យ ដោយសមហេតុផលថាជាទ្រព្យសម្បត្តិទាក់ទងនឹងបទល្មើសឬផលនៃបទល្មើស ។

**មាត្រា ៣០ថ្មី៤.- បណ្តឹងរបស់ជនជំទាស់នឹងសេចក្តីសម្រេច**

[illegible]ដែលជំទាស់នឹងសេចក្តីសម្រេចតាមបញ្ញត្តិមាត្រា៣០ថ្មី១ (ការបង្កកនិងការឃាត់ទុកទ្រព្យសម្បត្តិរបស់បុគ្គល) ឬមាត្រា៣០ថ្មី២ (ការរឹបអូសទ្រព្យសម្បត្តិ) ខាងលើនេះ ដែល

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL

សុំដកទ្រព្យសម្បត្តិដែលត្រូវបានសម្រេចឲ្យដក ឬរឹបអូសឬដែលសុំបដិសេធសេចក្តីសម្រេចនេះត្រូវតែបង្ហាញតុលាការថា ជននោះមានសិទ្ធិដោយត្រឹមត្រូវលើទ្រព្យសម្បត្តិនោះ ហើយទ្រព្យសម្បត្តិនោះមិនជាប់ពាក់ព័ន្ធនឹងបទល្មើសឬផលនៃបទល្មើស ។

**មាត្រា ៣០ថ្មី៥.- ការបង្កកមូលនិធិពាក់ព័ន្ធនឹងហិរញ្ញប្បទានភេរវកម្ម**

ទោះបីមានបទប្បញ្ញត្តិច្បាប់ផ្សេងទៀតក៏ដោយ មូលនិធិរបស់ភេរវកររបស់អ្នកផ្តល់ហិរញ្ញប្បទានភេរវកម្មនិងរបស់អង្គការភេរវកម្មដែលកំណត់ដោយសេចក្តីសម្រេចចិត្តរបស់ក្រុមប្រឹក្សាសន្តិសុខអង្គការសហប្រជាជាតិលេខ១២៦៧ និងលេខ១៣៧៣ និងសេចក្តីសម្រេចចិត្តបន្តបន្ទាប់ ត្រូវបានបង្កកដោយគ្មានពន្យារពេលតាមយន្តការនិងនីតិវិធីដែលមានកំណត់ដោយលិខិតបទដ្ឋានគតិយុត្ត ។

**មាត្រាពីរ.-**

ច្បាប់នេះត្រូវបានប្រកាសជាការប្រញាប់ ។

ធ្វើនៅព្រះបរមរាជវាំងថ្ងៃទី ០៣ ខែ មិថុនា ឆ្នាំ ២០១៣

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**

**នរោត្តម សីហមុនី**

នស.រកម.០៦១៣.៥៧៥

បានយកសេចក្តីក្រាបបង្គំទូលថ្វាយព្រះមហាក្សត្រ

សូមឡាយព្រះហស្តលេខា

នាយករដ្ឋមន្ត្រី

ហត្ថលេខា

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

បានយកសេចក្តីគោរពជម្រាបជូនសម្តេចអគ្គមហាសេនាបតីតេជោ

ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

អគ្គទេសាភិបាលធនាគារជាតិនៃកម្ពុជា

ហត្ថលេខា

ជា ចាន់តូ

លេខៈ ៥៦៧ ស.ណ

**សំណៅដែលបានតម្កល់ជាការចែកផ្សាយ**

រាជធានីភ្នំពេញ ថ្ងៃទី០៦ ខែមិថុនា ឆ្នាំ២០១៣

**អគ្គលេខាធិការរងទី១រាជរដ្ឋាភិបាល**

**សយ សុខា**